# អធិការក្រមុំ

កេសរគឺជាកុលាបមួយទង ដែលស្រស់ស្អាតជាងគេនៅទីក្រុងភ្នំពេញ។ នា ងមានរូបឆោមលោមពណ៌គួរជាទីពេញចិត្តរបស់មហាជន។ នាងមានសក់ខ្មៅរលោង សម្បុរស ស្បែករលោងម៉ដ្ឋខៃ ភ្នែកមូលក្រឡង់ ច្រមុះស្រួច បបូរមាត់ស្តើង និងមានត្រគាកវាវ ប៉ុន្តែនាងគឺជាកុលាបមានបន្លា។ នា ងឆ្នាសឆ្មើម វាយ ឫក ប៉ុន្តែពេលខ្លះដូចជាចិត្តល្អសួសរាយបន្តិចដែរតាមចរិតរបស់កូនស្រីអ្នកមាន។ កេសរជាកូនស្រីតែម្នាក់គត់របស់លោកគហបតី វិរៈវង្ស និងអ្នកស្រី យាណា ដែលជាអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភម្នាក់រស់នៅទីក្រុងភ្នំពេញ ទើបធ្វើឲ្យនាងអាចឆ្មើងឆ្មៃតាមចរិតរបស់នាងបាន។ នា ងតែងមានបំណងប្រាថ្នាក្នុងចិត្តថា នា ងនឹងក្លាយទៅជាប៉ូលិសស្រីដ៏ពូកែម្នាក់។ ឥលូវនាងទទួលបានជោគជ័យក្នុងជីវិតរបស់នាងហើយ គឺនាងបានក្លាយទៅជា ប៉ូលិសស្រីទីមួយនៅទីក្រុងភ្នំពេញ។ នា ងធ្លាប់បានបំបែកសំណុំរឿងរាប់មិនអស់។ នា ងតែងបានទទួលការស្ងើចសរសើរជាច្រើន ប៉ុន្តែនាងនៅមិនទាន់ពេញចិត្តនៅឡើយ ព្រោះតែនាងពុំទាន់បានទទួលងារជា កំ ពូលអធិការស្រី។ នៅស្នងការ កញ្ញា យើងកំពុងតែអង្គុយសញ្ជឹងគិតអំពីរឿងក្ដីមួយដែលនាងកំពុងតែតាមដាន ន ិងត្រួតពិនិត្យ។ នា ងតែបានទទួលដំណឹងយ៉ាងសម្ងាត់ពីជនអាថ៌កំបាំងម្នាក់ដែលនាងមិនស្គាល់ឈ្មោះ ហើយនៅពេលដែលទទួលបានដំណឹង នាង តែងតែបំបែកសំណុំរឿងក្ដីបានសម្រេចជានិច្ច។ កំពុងតែគិត ស្រាប់តែមានសំឡេងមួយបន្លឺឡើង៖

– កេសរ! កំពុងគិតរឿងអីហ្នឹង? បានជាភ្លឹកអីក៏ភ្លឹកម្ល៉េះៗ?
– អូ! លោករតនៈទេឬ? ខ្ញុំកំពុងតែគិតរឿងបន្តិចបន្តួច គ្មានអ្វីទេ។ និយាយអញ្ចឹង លោករកខ្ញុំមានការអ្វីដែរ?
– គ្មានអីទេ...គឺខ្ញុំចង់អញ្ជើញអ្នកនាងទៅញ៉ាំបាយហ្នឹងណា៎។
– ខ្ញុំអរគុណលោកច្រើនហើយ ប៉ុន្តែខ្ញុំនៅមានកិច្ចការខ្លះដែលមិនទាន់បញ្ចប់នៅឡើយ។
– អញ្ចឹងចាំពេលក្រោយចុះ។

និយាយចប់ លោកស្នងការកំលោះក៏ចាកចេញពីទីនោះ ដោយស្នាមញញឹម ពោរពេញដោយការខកចិត្ត។ នរៈរូបសង្ហាបើកឡាន BMW ឆ្ពោះទៅភោជនីយដ្ឋានយ៉ាងលឿន។ កំពុងតែសញ្ជឹងគិតពីរឿងកេសរដែលខ្លួនបានចាប់ចិត្តប្រតិព័ទ្ធជាយូរមកហើយ ស្រាប ់តែភ្លាមនោះនរៈបានជ្រុលចង្កូតទៅប៉ះនឹងនារីម្នាក់ដែលកំពុងតែធ្វើដំណើរស្របផ្លូវជាមួយរថយន្តរបស់រតនៈដែរ។ អ្នកកំលោះភ្ញាក់ស្មារតី ហើយបើកទ្វារឡានទៅជួយគ្រាប៉ហ៍នារីរងគ្រោះ។ នៅពេលដែលជួយគ្រាប៉ហ៍ កំលោះយើងសង្កេតឃើញថានាងមានសម្រស់មិនចាញ់កេសរប៉ុន្មានទេ។ នាងមានវង្វង់មុខមូលក្រឡង់ ភ្នែកធំៗពោរពេញទៅដោយក្ដីសង្ឃឹម សក់ខ្មៅរលោង ច្រមុះស្រួច បបូរមាត់ស្តើង សម្បុរសរលោងខ្ចី ចង្កេះរាងរៀវសមនឹងដងខ្លួន ធ្វើឲ្យអ្នកកំលោះភ្លឹកអស់មួយសន្ទុះ។ មា ណពបានបញ្ជូននាងទៅមន្ទីរពេទ្យដើម្បីរុំរបួស។ ក្រោ យពីរុំរបួសរួច អ្ន កកំលោះបានធ្វើការសុំទោសទៅដល់កញ្ញារងរបួស។ ក្រោ យមករតនៈក៏បានសួររកអាសយដ្ឋានរបស់កញ្ញាយើង។

– តើផ្ទះរបស់អ្នកនាងនៅឯណា? ទុកឲ្យខ្ញុំជូនអ្នកនាងទៅផ្ទះ។
– ទេ មិនអីទេ ខ្ញុំអាចទៅដោយខ្លួនឯងបាន។
– ប៉ុន្តែ វាជាកំហុសរបស់ខ្ញុំ ដែលធ្វើឲ្យអ្នកនាងរងរបួស ទុកឲ្យខ្ញុំជូនអ្នកនាងទៅវិញ។

ដោយការទទូចសុំខ្លាំងពេក កញ្ញា រូបស្រស់ក៏ព្រមឲ្យរតនៈជូនទៅផ្ទះ។ នៅ ក្នុងឡាន ពួក គេបានសំណេះសំណាលគ្នាបន្តិចបន្តួច។ កំ លោះហាក់មានអារម្មណ៍សប្បាយរីករាយប្លែក ដែលធ្វើឲ្យរតនៈមិនអាចបំភ្លេចបាននូវសំដីដ៏ទន់ភ្លន់ និងពីរោះរបស់បានឡើយ។ ពេលនេះ រតនៈ បើកឡានជាមួយនឹងអារម្មណ៍ដែលរំពឹងគិតទៅដល់រូបភាព និងសំឡេងដ៏ស្រទន់របស់នាងកញ្ញា។

ថ្ងៃនេះនៅស្នងការប៉ូលិស កេសរទទួលបានសំបុត្រអនាមិកមួយច្បាប់ដែលមានអត្ថន័យដូចតទៅ៖

*ខ្ញុំ បានទទួល ដំណឹង ថា ក្រៅ ស្នែក នឹង មាន ការ នាំចូល គ្រឿង ញៀន ខុស ច្បាប់ ជាច្រើនមក កាន់ប្រទេស យើង នៅព្រំប្រទល់ ប្រទេស វៀតណាម វេលា ម៉ោង ៩:០០។*

បន្ទាប់ពីបានទទួលសំបុត្រភ្លាម នា ងក៏បញ្ជាឲ្យកូនចៅរបស់នាងធ្វើដំណើរទៅកាន់ព្រំប្រទល់ប្រទេសវៀតណាមជាបន្ទាន់។ នៅ ពេលដែលពួកឈ្មួញទុច្ចរិតបានឆ្លងចូលមកដល់ដីខ្មែរ កង កម្លាំងប៉ូលិសរបស់យើងបានព័ទ្ធចាប់ជនល្មើសនៅនឹងកន្លែង ហើយបានបញ្ជូនពិរុទ្ធជនទាំងនោះទៅកាន់តុលាការក្រុងភ្នំពេញបានដោយជោគជ័យ។ ប៉ុន្តែមាណវីនៅតែពុំទាន់អស់ចិត្តពីព្រោះតែនាងទទួលបានជោគជ័យរាល់បេសកកម្មដោយសារតែសំបុត្រអនាមិកមួយច្បាប់។ នាងព្យាយាមស្វែងរកម្ចាស់ព័ត៌មានជានិច្ច។ ជាអកុសល នាងនៅតែពុំអាចស្គាល់ជនអាថ៌កំបាំងម្នាក់នោះបានឡើយ។

នៅល្ងាចថ្ងៃសៅរ៍ នៅ តាមមាត់ទន្លេមានមនុស្សច្រើនកុះករបានមកលំហែកាយស្រូបយកខ្យល់អាកាស។ បេ ីយើងសង្កេតមើលឲ្យច្បាស់ យើ ងនឹងបានឃើញកំលោះរូបសង្ហាម្នាក់ កំពុ ងអង្គុយសញ្ជប់សញ្ជឹងហាក់គិតដល់រឿងអ្វីមួយ។ កំលោះម្នាក់នោះមានរូបរាងស្អាតសង្ហា ភ្នែ កធំៗ ច្រមុះស្រួចដូចកូនកាត់ ចង្កាព្រែក ស្មាបើក ខ្ពស់ស្រឡះ។ ទោះជាគេស្លៀកសំលៀកបំពាក់ប្រឡាក់ប្រឡូសក៏ដោយ ក៏នៅតែមិនអាចបិទបាំងភាពសង្ហារបស់គេបានឡើយ។ នៅ ក្បែរនោះ មា ណពបានក្រឡេកឃើញ ជនអន្ធពាលមួយក្រុមកំពុងតែ ជំរិតទារលុយកុមារាម្នាក់។ នរៈទ្រាំមិនបាននឹងទង្វើដ៏អាក្រក់នេះ ក៏ចេញមុខទៅជួយកុមារាម្នាក់នោះ។ នៅ ឯម្ខាងទៀត ភ្នែ កមួយគូកំពុងតែសម្លឹងមើលទៅកាន់ព្រឹត្តិការណ៍នោះដោយយកចិត្តទុកដាក់។ គឺ កេសរ នាងឃើញថាជនអន្ធពាលមួយក្រុមនោះហាក់ដូចជាខ្លបខ្លាចនឹងរឹទ្ធិអំណាចរបស់កំលោះរូបសង្ហានេះ។

# ខួបកំណើតដ៏ជូរចត់

កេសរកំពុងតែឈរនៅរានហាលខាងមុខផ្ទះ យ៉ាងអណ្តែតអណ្តូងហាក់នឹងគិតទៅដល់ព្រឹត្តិការណ៍កាលពីល្ងាចមិញជាមួយនឹងបុរសរូបសង្ហាដែលនាងដូចជាមាននិស្ស័យ និងធ្លាប់ឃើញនៅកន្លែងណាម្តង។ ភ្លាមនោះ នាងគិតពីវ័យកុមារភាពដែលកុមារាម្នាក់បានសន្យាថានឹងដណ្តឹងនាងធ្វើជាប្រពន្ធ ហើយថានឹងធ្វើជាប៉ូលិសដែលមានឋានៈលើសនាងថែមទៀត។ កេសរនៅចាំពាក្យនេះជានិច្ច មិនអាចបំភ្លេចបានឡើយ។ គិតដល់ត្រឹមនេះ ស្រាប់តែមានសំឡេងមួយបន្លឺឡើង៖

- កេសរ!!! កំពុងគិតអីហ្នឹង?
- អូ! កញ្ញានាទេ ខ្យល់អីបកឯងមកដល់ផ្ទះគ្នា?
- គឺគ្នាចង់ហៅឯងទៅពិធីខួបកំណើតគ្នាហ្នឹងណ៎ា។
- វាធ្វើនៅថ្ងៃណា? ពេលណា? រួចកន្លែងណាដែរ?
- ធ្វើនៅថ្ងៃទី ២៩ កក្កដា គឺថ្ងៃខាងស្អែកនេះ វេលាម៉ោង ៤:៣០ នាទីនៅផ្ទះរបស់គ្នា។
- អញ្ចឹងចាំគ្នាទៅ។ និយាយអញ្ចឹង ឯងសព្វថ្ងៃធ្វើការអ្វីដែរបានជាមិនសូវឃើញមកលេងគ្នាសោះ?
- គឺគ្មានធ្វើការអីទេ គ្រាន់តែជួយមើលកិច្ចការក្រុមហ៊ុនខ្លះៗ។ ចំណែកឯងក៏មិនឃើញទៅលេងគ្នាដែរ រវល់ខ្លាំងមែនទេ ភារកិច្ចជាប៉ូលិសស្រី?
- ម៉េចក៏ឯងដឹងថាគ្នាធ្វើជាប៉ូលិស?
- នរណាមិនដឹង បើល្បីពេញទីក្រុងភ្នំពេញទៅហើយ។
- មានឯណា ចេះតែថាហ្នឹង។

ពួកគេសំណេះសំណាលគ្នាមួយសន្ទុះ កញ្ញានាក៏លាកេសរត្រលប់ទៅផ្ទះវិញ។ អ្នកនិពន្ធភ្លេចប្រាប់ កញ្ញានាគឺជាមិត្តរបស់កេសរ និងថាវីកាលនៅរៀនមហាវិទ្យាល័យ។ កញ្ញានាគឺជាកូនរបស់លោកពិសិដ្ឋនរះដែលជាមេបញ្ជាការរបស់វិរៈយុទ្ធ។ ដោយសារតែរូបរាង ដ៏សង្ហារបស់វិរៈយុទ្ធ ធ្វើឲ្យកញ្ញានាចាប់ចិត្តទៅលើកំលោះ តែកំលោះពុំមានចាប់ចិត្តទៅលើនាងវិញទេ។ គេចាត់ទុកនាងគ្រាន់តែជាប្អូនស្រីតែប៉ុណ្ណោះ។ កញ្ញានាក៏បានហៅថាវីរតនៈ និងវិរៈយុទ្ធទៅចូលរួមពិធីខួបកំណើតរបស់នាងដែរ។

ថ្ងៃខួបកំណើតរបស់កញ្ញានាមកដល់ ភ្ញៀវមកដល់ជាបន្តបន្ទាប់។ កញ្ញានាសែនស្រស់ ស្ថិតនៅក្នុងសំលៀកបំពាក់ពណ៌ស្វាយរំលេចដោយខ្សែកពេជ្រភ្លឺចិញ្ចែងចិញ្ចាច សក់បួងឡើងជាមួយសាច់ដ៏សខ្ចី និងរង្វង់មុខពងក្រពើ ធ្វើឲ្យបុរសជាច្រើនភ្លឹកស្មារតីទ្រាំមិនបាននឹងសម្រស់របស់កញ្ញានា។ ភ្លាមនោះ កេសរមកដល់ល្មម ព្រមគ្នាជាមួយវិរៈយុទ្ធ ដែលធ្វើឲ្យក្រសែភ្នែកមនុស្សទាំងប្រុសទាំងស្រី ទាំងក្មេងទាំងចាស់ ជាមួយនឹងភ្នែកមួយគូរបស់កញ្ញានា ផ្តោតទៅមើលកំលោះក្រមុំមួយគូនេះឥតព្រិចភ្នែក។ សម្តីអ្នកទាំងអស់គ្នាពោលមិនដាច់ពីមាត់ ពិតជាសក្តិសមគ្មានអ្វីទាស់ ទាំងរូបរាង ទាំងកម្ពស់ ព្រមជាមួយនឹងរង្វង់មុខរលោងដូចពងមាន់ ឯបបូរមាត់ក្រហមឆ្អៅជាមួយនឹងខ្សែករូបបេះដូងធ្វើឲ្យកញ្ញារបស់យើងស៊ីដាច់អស់នារីដែលបានទៅចូលរួមពិធី ដាច់ទាំងកញ្ញានាដែលនៅឈរស្រឡាំងកាំង។ ពេលឃើញវិរៈយុទ្ធដែលខ្លួនស្រឡាញ់ ដើរមកព្រមគ្នាជាមួយកេសរ នាងមានការមិនពេញចិត្តនឹងកេសរជាខ្លាំង។

លោករតនៈកំពុងឈរសំណេះសំណាលនឹងថាវី មួយគូនេះក៏មិនចាញ់កេសរ និងវិរៈយុទ្ធប៉ុន្មានដែរ។ កំពុងតែនិយាយគ្នា កញ្ញានាក៏ហៅរតនៈ ថាវី កេសរ និងវិរៈយុទ្ធ ចូលទៅញ៉ាំអី។ ពេលវេលាកាត់នំក៏មកដល់ ពួកគេជូនពរកញ្ញានាគ្រប់គ្នា ធ្វើឲ្យកញ្ញានារីករាយឥតឧបមា។ ពិធីកាត់នំរួចរាល់ ឈានចូលទៅដល់ ការរាំរែក កញ្ញាកញ្ញានារង់ចាំវិរៈយុទ្ធសុំខ្លួនឡើងរាំ ប៉ុន្តែផ្ទុយទៅ

វិញ វិរៈយុទ្ធបែរជាសុំកេសរឡើងរាំទៅវិញ៖

– កេសរ! អាចផ្ដល់ឱកាសឲ្យខ្ញុំសុំអ្នកនាងឡើងរាំបានទេ?

ដោយមិនចង់ឲ្យវិរៈយុទ្ធខ្មាសគេ និងសម្ដីពន្យុះរបស់ភ្ញៀវដទៃទៀត កេសរក៏យល់ព្រមរាំជាមួយវិរៈយុទ្ធ។ ពួកគេរាំមួយបទហើយមួយបទទៀត មិនចេះចប់មិនចេះហើយ។ កញ្ញានារិញ ខាំមាត់សឹងដាច់តឹងទ្រូងស្ទើរបែកចេញមកក្រៅ។ ឯកំលោះក្រមុំទាំងពីរសែនសប្បាយធ្វើឲ្យកេសរភ្លេចអស់ទុក្ខកង្វល់នានា និងភាពនឿយហត់ពីការងារ។ ពួកគេរាំជាមួយនឹងការសើចសប្បាយធ្វើឲ្យគេទាំងអស់គ្នាមើលមកមួយគូនេះឥតដាក់ភ្នែក។ កម្មវិធីត្រូវបានបញ្ចប់ រតនះបានសុំខ្លួនជូនថាវីទៅផ្ទះ។ អ្នកកំលោះយើងឥលូវ ហាក់ចាប់ចិត្តទៅលើថាវីហើយ។ យើងបែរមកនិយាយពីកេសរ និងវិរៈយុទ្ធវិញម្ដង។

– និយាយអញ្ចឹង តើលោកជានរណា? ខ្ញុំដូចជាធ្លាប់ឃើញនៅឯណាម្ដង។
– ចុះបើមិនស្គាល់ខ្ញុំផង ម៉េចរាំជាមួយខ្ញុំធ្វើអី?
– កុំឲ្យលោកខ្មាសគេហ្នឹងណា។ ខំធ្វើល្អ បែរជាបានទោសទៅវិញ។
– ខ្ញុំស្មានតែស្រឡាញ់ខ្ញុំ ខំតែដេកអរ។
– ច្រឡំមាត់ទេអ្វី? ថាខ្ញុំស្រឡាញ់ ដេកយល់សប្តិទៅ។
– យី! សំដីថ្លោសផង! ប្រយ័ត្នតែបានខ្ញុំធ្វើប្ដី តិចបាត់មុខមិនបានទៅ។
– បើយកលោកធ្វើប្ដី សុខចិត្តនៅទំនេរវិញល្អជាង។

កំពុងតែនិយាយគ្នា ពួកគេដើរមកដល់ឡានល្មម។ ពួកគេក៏បែកផ្លូវគ្នាទៅផ្ទះរៀងខ្លួន។ វិរៈយុទ្ធបើកឡាន Lexus តម្រង់ទៅគេហដ្ឋាន ស្រាប់តែប្រទះឃើញឡានកេសរខូចនៅកណ្ដាលផ្លូវ។ នរៈឈប់ឡានភ្លាម ចុះទៅជួយមើលឡានរបស់កេសរ រួចក៏បន្លឺសំឡេងឡើង៖

– ម៉េច! ជួបគ្នាទៀតហើយ។ ខ្ញុំថាអ្នកនាង និងខ្ញុំពិតជាមាននិស្ស័យនឹងគ្នាមិនខាន បើទើបតែបែកគ្នាអំបាញ់មិញនេះសោះ។ ប្រហែលជានឹកខ្ញុំខ្លាំងហើយមើលទៅ បានជាឈប់នៅកណ្ដាលផ្លូវតែម្ដង។
– លោកអត់ភ្នែកទេហ្អី បានជាមើលមិនឃើញឡានខ្ញុំខូច?
– បើខ្ញុំអត់ភ្នែក នោះអ្នកនាងនឹងត្រូវពិបាកទៅហើយ ព្រោះថានៅចាំមើលថែស្វាមីពិការភ្នែកម្នាក់នេះ។ (និយាយបែបហឺ)

ដោយមិនបង្អង់ពេលយូរ វិរៈយុទ្ធក៏បានទៅជួយពិនិត្យឡានរបស់កេសរ ក្រែងលោអាចជួសជុលបាន ប៉ុន្តែដោយសារតែរថយន្តខូចខាតធ្ងន់ធ្ងរពេកទើបមិនអាចជួសជុលបាន ទើបនរៈហៅកេសរឲ្យឡើងជិះឡានជាមួយខ្លួន។

– អូនសម្លាញ់! ឡើងឡានមក ចាំបងជូនទៅផ្ទះ។ ចាំទូរស័ព្ទហៅសូហ្វ័រមកយកឡាន។
– ហៅនរណាអូនសម្លាញ់? ខ្ញុំមិនទៅជាមួយលោកឯងទេ! ទៅម្នាក់ឯងចុះ!

ដោយសារតែកេសរមិនព្រមទៅជាមួយវិរៈយុទ្ធ មា ណពក៏បើកឡានចេញទៅបាត់ ទុកឲ្យកេសរនៅតែម្នាក់ឯង។ ជួនជាពេលនោះ មា នជនអន្ធពាលមួយក្រុម ប្រហែលមានគ្នាប្រាំទៅប្រាំមួយនាក់ បា នដើរតម្រង់មករកកេសរ។ ដំ បូង កេសរមានអារម្មណ៍នឹងនថានាងអាចទប់ទល់នឹងពួកគេបាន។ ដោយសារតែកេសរស្ថិតនៅក្នុងសំលៀកបំពាក់ឈុតរាត្រី ទើបធ្វើឲ្យនាងមិនអាចទប់ទល់នឹងពួកគេបាន។ ស្រាប់ តែពេលនោះ លេចចេញបុរសរូបសង្ហាម្នាក់។ ការ ពិតគឺជាវិរៈយុទ្ធដែលមិនដឹងមកតាំងពីអង្កាល់។ នរៈ ទាញដៃកេសរឡើងឡាន រួចក៏បើកចេញយ៉ាងលឿនតម្រង់ទៅរកកន្លែងដែលមិនសុវត្ថិភាព។ កំលោះរបស់យើងក៏បន្លឺសំឡេងឡើង៖

– ម៉េច? ហៅឡើងឡានតាំងពីដំបូងមិនព្រម ទាល់តែអញ្ចឹងបានសម។
– បើលោកមិនមក ក៏ខ្ញុំអាចឈ្នះពួកហ្នឹងបានដែរ។ កុំតែលោកអូសខ្ញុំឡើងឡាន កុំអីខ្ញុំប្រដៅពួកហ្នឹងឲ្យដឹងដៃម្ដង។

- ដឹងអញ្ចឹង មិនខ្វីជួយទេ។
- តែយ៉ាងណា ក៏នៅតែត្រូវអរគុណលោកដែរ។
- មិនបាច់អរគុណទេ យើជាគ្រួសារតែមួយហ្នឹង។
- នរណាជាគ្រួសារតែមួយជាមួយលោក មិនតឹងទាន់ស្គាល់ឈ្មោះផង។
- ឈ្មោះបង អូនមិនបាច់ស្គាល់ទេ ចាំតែបានគ្នាជាប្ដីប្រពន្ធ ចាំស្គាល់ទាំងឈ្មោះ ស្គាល់ទាំងចិត្តតែម្ដង។

រថយន្តរំកិលខ្លួនយ៉ាងសន្សឹមៗ បើកកាត់ស្បៃអន្ធការ។ ពួក គេគយគន់ទេសភាពយ៉ាងស្ងប់ស្ងាត់ ធ្វើឲ្យកេសរមានអារម្មណ៍ថាខ្លួនហាក់ដូចជាចាប់ចិត្តទៅលើអ្នកកំលោះ។ រ ថយន្តបើកមកដល់ផ្ទះកេសរ។ កេសរបានហៅវិរៈយុទ្ធចូលទៅលេង ប៉ុន្តែដោយសារតែយប់ជ្រៅណាស់ទៅហើយ នរះក៏លាកេសរត្រលប់មកផ្ទះខ្លួនវិញ។

# ស្នេហាកើតក្រោយឧប្បត្តិហេតុ

នៅស្នងការប៉ូលិស កញ្ញាកេសរបានទទួលសំបុត្រមួយច្បាប់ទៀតហើយ ដែលមានសេចក្តីដូចតទៅ៖

> *ខ្ញុំ បានទទួល ដំណឹង ថា មាន ការ ប្លន់ធនាគារ មួយ យ៉ាង ធំនៅ វេលា ម៉ោង ៩:០០ ធនាគារ វិភព លោក ព្រឹក ស្អែក នេះ។*

ក្រោយពីទទួលបានសំបុត្រ កេសរកោះហៅរតនៈដើម្បីធ្វើការប្រជុំរៀបគម្រោងការចាប់ជនឧក្រិដ្ឋភ្លាម។

ព្រឹកស្អែកមកដល់ កេសររៀបចំគម្រោងការរួចជាស្រេច រង់ចាំតែពួកជនឧក្រិដ្ឋប៉ុណ្ណោះ។ នៅធនាគារពិភពលោក ពិតជាមានក្រុមចោរមួយក្រុមមែន ប៉ុន្តែពួកគេបិតមុខដោយក្រណាត់ខ្មៅ ធ្វើឲ្យក្រុមប៉ូលិសមិនដឹងថាជាអ្នកណា។ ពួកក្រុមចោរធ្វើការប្លន់ដោយចាប់ចំណាប់ខ្មាំងជាច្រើន។ កេសរបញ្ជាកុំឲ្យក្រុមប៉ូលិសមានសកម្មភាពអ្វីទាំងអស់ ព្រោះខ្លាចធ្វើឲ្យចំណាប់ខ្មាំងរងរបួស និងបាត់បង់ជីវិត។ រតនៈក៏មកដល់។ រតនៈលើកទូរស័ព្ទ៖

- អាឡូ! វិរៈយុទ្ធ ចាប់ផ្តើមផែនការរបស់យើងទៅ។
- បាន ខ្ញុំនឹងចាត់ការភ្លាម។ តែឯងត្រូវមើលកេសរផង ប្រយ័ត្នមានគ្រោះថ្នាក់។
- យើងដឹងហើយ។

បើយើងសង្កេតឲ្យច្បាស់យើងឃើញក្រុមចោរប្រមាណដប់នាក់ ប្រដាប់ដោយអាវុធ ស្រាប់តែក្រុមចោរបាត់សមាជិកម្នាក់ ពេលដែលរតនៈកំពុងតែនិយាយទូរស័ព្ទ។

និយាយពីក្រុមចោរ មេបញ្ជាការបានប្រគល់ចំណាប់ខ្មាំងទៅឲ្យជំនិតរបស់ខ្លួនជាអ្នកត្រួតពិនិត្យ។ មួយសន្ទុះក្រោយមកគេប្រទះឃើញ ចំណាប់ខ្មាំងចេញតាមទ្វារក្រោយម្តងម្នាក់ៗ ទាល់តែអស់។ កេសរមិនបង្អង់ទេ ចាត់ការភ្លាម។ ប៉ូលិសធ្វើការប្រយុទ្ធជាមួយក្រុមចោរយ៉ាងស្វិតស្វាញអស់មួយសន្ទុះ ធ្វើឲ្យកេសរចាប់បានចោរទាំងអស់ ចាប់ទាំងវិរៈយុទ្ធថែមទៀត ព្រោះតែនាងមិនបានដឹងរឿង។ កេសរបានបញ្ជាឲ្យកូនចៅរបស់នាងបើកមុខជនអន្ធពាលទាំងនោះ។ អ្វីដែលនាងមិននឹកស្មាន មេបញ្ជាការរបស់ក្រុមចោរគឺជាលោកពិសិដ្ឋនរៈ ដែលត្រូវជាឪពុករបស់សត្យា និងកញ្ញានាសោះ។ អ្វីដែលមិនគួរឲ្យជឿថែមទៀតគឺវិរៈយុទ្ធដែលកេសរស្រឡាញ់ក៏បង្ហាញមុខនៅទីនេះដែរ។ កេសរស្ទើរស្ទះបេះដូង ឈរភ្លឹកដូចមនុស្សរុក្ខជាតិអស់មួយសន្ទុះ ទឹកនេត្រារមៀលស្រក់ឥតឈប់ ហាក់ស្តាយស្រណោះនឹងចិត្តដែលបានស្រឡាញ់មនុស្សខុស។ ស្រាប់តែពេលនោះ លោកពិសិដ្ឋនរៈយាកាំភ្លើង បម្រុងនឹងបាញ់កេសរ។ ភ្លាមនោះ វិរៈយុទ្ធបានមករងគ្រាប់កាំភ្លើងជំនួសកេសរ។ វិរៈយុទ្ធដួលទៅលើដី សឹងដាច់ខ្យល់។ រតនៈបានចាប់លោកពិសិដ្ឋនរៈ ហើយបញ្ជូនទៅកាន់តុលាការ។ និយាយពីវិរៈយុទ្ធនៅលើដៃស្រស់ស្រីកេសរ ដោយដឹងថាខ្លួនមិនអាចរស់ទៀតបាន ទើបទម្លាយអាថ៌កំបាំងដែលលាក់ជាយូរមកហើយប្រាប់កេសរថាខ្លួនបានស្រលាញ់កេសរ គឺខ្លួនជាកុមារាម្នាក់ដែលធ្លាប់បានសន្យានឹងកេសរកាលពីនៅតូច ថានឹងយកកេសរធ្វើជាប្រពន្ធ និងធ្វើជាប៉ូលិសដែលមានឋានៈលើសនាងថែមទៀត។

- កេសរ! ខ្ញុំគឺវិរៈយុទ្ធ ដែលធ្លាប់បានសន្យាជាមួយនាងនោះអី។ (និយាយខ្សាវៗ)
- បងកុំនិយាយអី ខ្ញុំនឹងបញ្ជូនបងទៅមន្ទីរពេទ្យ។ បងនឹងបានជាវិញមិនខាន។
- មិនអាចទៅរួចទេ។ បើបងមិននិយាយ បងខ្លាចមិនអាចនិយាយជារៀងរហូត។ បងស្រឡាញ់អូន។

ដោយនេះជាពេលចុងក្រោយទៅហើយ កេសរក៏ប្រាប់វិរៈយុទ្ធវិញថា៖

- ខ្ញុំក៏ស្រឡាញ់បងដែរ។ ខ្ញុំស្រឡាញ់បងជាយូរមកហើយ។ តើហេតុអ្វីបានជាបងមកធ្វើជាចោរទៅវិញ?
- ទេ បងគឺជា...

និយាយដល់ត្រឹមនេះ វិរៈយុទ្ធក៏សន្លប់បាត់ទៅ។ កេសរក៏បញ្ជូនវិរៈយុទ្ធទៅកាន់មន្ទីរពេទ្យ។ កេសរបានដឹងរឿងទាំងអស់ពីរតនៈដែលថាវិរៈយុទ្ធគឺជាលោកស្នងការដ៏មានថ្វីដៃជាងគេនៅទីក្រុងភ្នំពេញ ដោយសារតែត្រូវការបំបែកសំណុំរឿង ទើបបង្ខំខ្លួនធ្វើជាភ្នាក់ងារសម្ងាត់។ ការពិតជនដែលផ្ញើសំបុត្រឲ្យកេសរគឺជាវិរៈយុទ្ធ បានជាវិរៈយុទ្ធស្គាល់កេសរបានច្បាស់ម្ល៉េះ។ វិរៈយុទ្ធបានរួចផុតពីសេចក្តីស្លាប់ហើយ។ ពេលនេះ កំពុងតែសម្រាកនៅមន្ទីរពេទ្យជាមួយនឹងថ្នាំដ៏ស័ក្តិសិទ្ធិគឺស្រស់ស្រីកេសរដែលនៅចាំមើលថែរក្សាវិរៈយុទ្ធ។ ពេលនេះវិរៈយុទ្ធជាសះស្បើយហើយ។ នរៈស្លៀកសំលៀកបំពាក់ជាលោកស្នងការកំលោះ ធ្វើឲ្យនារីទូទាំងភ្នំពេញមើលសឹងជ្រុះភ្នែកពីដី។ កេសរវិញបានក្លាយទៅជាកំពូលអធិការស្រីទីមួយនៅទីក្រុងភ្នំពេញ។

ថ្ងៃនេះគឺជាថ្ងៃរៀបអាពាហ៍ពិពាហ៍របស់រតនៈ និងថាវរី។ ភ្ញៀវជាច្រើនកុះករពាសពេញរោងការ នៅតែមិនទាន់ឃើញវិរៈយុទ្ធ និងកេសរមកសោះ។ ថាវរីនិយាយទៅកាន់រតនៈ៖

- ថ្មើនេះទៅហើយ នៅមិនទាន់ឃើញកេសរទៀត។
- វិរៈយុទ្ធក៏មិនទាន់ឃើញមកដែរ។ សង្ស័យតែនៅសំណេះសំណាលគ្នាទេមើលទៅ។

និយាយមិនទាន់ចប់ផង ស្រាប់តែឃើញវិរៈយុទ្ធបណ្តើរកេសរចូលមក ធ្វើឲ្យមនុស្សពេញរោងការមើលមិនដាក់ភ្នែក។ នៅឯជ្រុងម្ខាងនៃវេទិកា គេឃើញកំលោះរូបសង្ហាម្នាក់មិនចាញ់វិរៈយុទ្ធ និងរតនៈប៉ុន្មាន កំពុងសំណេះសំណាលជាមួយកញ្ញា គឺសត្យាដែលត្រូវជាកូនរបស់លោកពិសិដ្ឋនរៈដែលទើបតែត្រលប់មកពីអង់គ្លេសបានប៉ុន្មានថ្ងៃ។ សត្យា ក៏បានចាប់ចិត្តស្រឡាញ់កេសរដែរ។ ពេលកេសរចូលទៅអង្គុយក្នុងតុ សត្យាមិនបង្អង់ទេ បានសុំកេសរឡើងរាំ។ ដោយសារតែកេសរចង់បញ្ឈឺវិរៈយុទ្ធ ក៏ព្រមរាំជាមួយនឹងសត្យា។ វិរៈយុទ្ធវិញខឹងនឹងកេសរខ្លាំងណាស់ ក៏ទៅអញ្ជើញកញ្ញានាឡើងរាំជាមួយ ដើម្បីបញ្ឈឺកេសរវិញ។ ពួកគេទាំងពីរនាក់ចេះតែបញ្ឈឺគ្នាទៅវិញទៅមក ធ្វើឲ្យរតនៈ និងថាវរីឆ្ងល់ជាខ្លាំង។ កម្មវិធីត្រូវបានបញ្ចប់នៅម៉ោង ១២:០០ យប់។ ពេលនេះ វិរៈយុទ្ធសុំខ្លួនជូនកេសរទៅផ្ទះ ប៉ុន្តែកេសរប្រកែក ព្រោះនាងបានឲ្យសូហ្វ័រឡានរង់ចាំនាងនៅខាងក្រៅ។

- អញ្ចឹង អូនប្រញាប់ទៅផ្ទះចុះ ព្រោះយប់ជ្រៅហើយ។ (វិរៈយុទ្ធនិយាយ)

និយាយចប់ វិរៈជូនកេសរទៅឡាន រួចក៏បើកឡានត្រលប់ទៅគេហដ្ឋានរបស់ខ្លួនវិញ។ ជិះបានពាក់កណ្តាលផ្លូវ ស្រាប់តែទូរស័ព្ទចាប់រោទិ៍។

- អាឡូ! លោកស្នងការ! ពេលនេះ មានឡានមួយគ្រឿងឈប់នៅពាក់កណ្តាលផ្លូវជាមួយនឹងបុរសម្នាក់កំពុងតែដួលសន្លប់។
- តើមានរឿងអ្វីកើតឡើង? (វិរៈយុទ្ធគំហក)
- បុរសម្នាក់នោះនិយាយថាមានក្រុមចោរមួយក្រុមបានចាប់ម្ចាស់ស្រីរបស់គាត់ទៅដោយវាយឲ្យគាត់សន្លប់។
- អញ្ចឹងខ្ញុំនឹងទៅភ្លាម។

មកដល់កន្លែងកើតហេតុ គឺឡានកេសរ នាយស្នងការបានរត់មកប្រាប់វិរៈយុទ្ធទាំងស្លន់ស្លោរ។ អម្បាញ់មិញនេះ ពួកគេបានចាប់នារីម្នាក់បាត់ហើយ។ នរៈលើកទូរស័ព្ទ៖

- អាឡូ! លោកពូវិរៈវង្សនិយាយមែនទេ?
- មែនហើយ ខ្ញុំគឺវិរៈវង្ស។
- ពេលនេះ គេបានចាប់កេសរទៅបាត់ហើយ។

លោកជ្រុះទូរស័ព្ទពីដៃ រួចប្រញាប់ប្រញាល់ទៅកន្លែងកើតហេតុ។ ពេលនេះ ម៉ោង ៧:៣០ នាទី វិរៈយុទ្ធកំពុងស្រាវជ្រាវរក

ភស្តុតាងដើម្បីចាប់ជនដៃដល់ ស្រាប់តែទូរស័ព្ទវិរៈយុទ្ធរោទិ៍ឡើង៖

– អាឡូ! វិរៈយុទ្ធហ្មេ! យើងនឹងបានជួបគ្នាក្នុងពេលឆាប់ៗនេះ ព្រោះថាកេសរនៅក្នុងដៃរបស់យើង។

– អាឡូ! ឯងជាអ្នកណា? ពេលនេះកេសរយ៉ាងម៉េចទៅហើយ? បើនាងមានគ្រោះថ្នាក់ យើងនឹងមិនលើកលែងឲ្យឯងទេ។

– នាងគ្មានគ្រោះថ្នាក់ទេ។ មនុស្សដែលយើងត្រូវការគឺឯង មិនមែននាងទេ។ ឯងឆាប់មកជួបយើងនូវអគារមួយដែលខ្ពស់ជាងគេនៅម្តុំផ្សារចាស់។ យើងទុកពេលឲ្យឯង ៣០ នាទីជាមួយនឹងឪពុករបស់យើង។ បើលើសតែមួយនាទី យើងនឹង...ឯងប្រាកដជាដឹងហើយមែនទេ។

– កុំធ្វើអីនាងឲ្យសោះ។ យើងនឹងទៅភ្លាម។

ឡានវិរៈយុទ្ធបើកដូចហោះតម្រង់ទៅម្តុំផ្សារចាស់ ជាមួយនឹងឪពុករបស់សត្យា។ ពេលនេះម៉ោង ៧:៥៧ នាទីហើយ វិរៈយុទ្ធប្រញាប់នាំលោកពិសិដ្ឋនរៈទៅជួបនឹងសត្យា។ ពេល ទៅដល់ សត្យា ធ្វើការដោះដូរកេសរ នឹងវិរៈយុទ្ធ។ រួចសត្យាបន្លឺសំឡេងឡើង៖

– យើងក៏ស្រឡាញ់កេសរដែរ បើមិនអញ្ចឹង យើងប្រកួតគ្នាមើលទៅ នរណាឈ្នះ អ្នកណាចាញ់។

– យុទ្ធ! បងកុំប្រកួតអី! (កេសរនិយាយ)

– មិនអីទេ! បងប៉ូលិសក៏ធ្លាប់ធ្វើ ចោរក៏ធ្វើហើយដែរ ខ្លាចអីប៉ុណ្ណឹង។

– ពិតជាសមជាកូនប្រុសមែន។

ពួកគេទាំងពីរនាក់ប្រកួតគ្នាយ៉ាងស្វិតស្វាញ ទុកឲ្យកេសរ និងលោកពិសិដ្ឋនរៈឈរមើល។ និយាយពីរតនៈវិញ កំពុងដឹងនាំក្រុមប៉ូលិសស្កាត់ចាំនៅខាងក្រោមរួចជាស្រេច ចាំតែសញ្ញារបស់វិរៈយុទ្ធ ប៉ុន្តែជាអកុសល ដោយសារតែវិរៈយុទ្ធមានបទពិសោធច្រើនក្នុងការចាប់ចោរ សត្យាក៏ត្រូវចាញ់ក្រោមដៃវិរៈយុទ្ធដោយមិនអស់ចិត្ត។ វិរៈយុទ្ធក៏បញ្ជាឲ្យរតនៈចាប់សត្យា និងឪពុកពីបទចាប់ជំរិត។